# កិច្ចសំភាសន៍របស់អ៊ុំស្រីឈ្មោះ ទូច សំណាង

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ទូច សំណាង

កៈ ចាសជាដំបូងសុំជំរាបសួរអ៊ី!

ខៈ ចាសអរគុណ ក្មួយមានការអី?

កៈ ចាសអ៊ីថ្ងៃនេះខ្ញុំស្ម័គ្រចិត្តមកពីខាងគំរោងរបស់សាលា BYU ហាវ៉ៃនៃសហរដ្ឋអាមេរិចហើយខ្ញុំមានឳកាសដើម្បីនិងសំភាសន៍អ៊ីទាក់ទងនឹងប្រវត្តិរបស់អ៊ី បទពិសោធន៍ជីវិតរបស់អ៊ីដែលធ្លាប់ឆ្លងកាត់រហូតមកដល់ឥលូវហើយការសំភាសន៍មួយនេះគេនឹងយកទៅដាក់នឹងផុសនៅក្នុងវេបសាយរបស់ចខាងសាលាហើយការសំភាសន៍ធ្វើឡើងនៅក្នុងថ្ងៃទី១២ ខែ៦ ឆ្នាំ២០១៨ (សំលេងរំខានពីខាងក្រៅ)នេះផ្ទាល់តែម្តងចឹងអ៊ីអនុញ្ញាតអោយខ្ញុំដើម្បី Record សំលេងរបស់អ៊ីហើយយកសំលេងរបស់អ៊ីទៅដាក់នៅក្នុងខាងវេបសាយដែរឬទេ?

ខៈ គេសំភាសន៍អីគេអូន ពីប្រវត្តិមកនឹងប្រវត្តិអាពតនឹងមកហ្អែស?

កៈ ចាសអ៊ីគោលបំណងនៃការសំភាសន៍មួយនេះគេទាក់ទនជាមួយនឹងប្រវត្តិរបស់អ៊ីអ៊ី.....ដូចជាពង្សប្រវត្តិ អ៊ី...ក្រុមគ្រួសារនឹងអ៊ី.....ប្រវិត្តិអ៊ីដូចថាមានអ៊ី....ជីវិតបែបណាដើម្បីអ៊ី....យកប្រវត្តិទាំងអស់នឹងមកចងក្រងជាឯកសារដើម្បីអោយកូនចៅជំនាន់ក្រោយនឹងស្តាប់បានដឹងជាពិសេសកូនចៅរបស់អ៊ីដែលគាត់បានចូលទៅក្នុងវេបសាយនឹងហើយគាត់បើកស្តាប់បានដោយគ្រាន់តែវាយ www.byuhavaii.khmeroralhistory ទៅគាត់នឹងឃើញវេបសាយនឹងហើយគាត់អាចនឹងចូលទៅក្នុងអ៊ីៗ....មានៗ....Categoryនៅក្នុងនឹងច្រើនចឹងគាត់អាចចូលទៅក្នុងកន្លែងដាក់ដូចជា Interview ហើយមានអ៊ី....ដូចជាសំលេងអីផ្សេងៗចឹងនៅក្នុងមានសំលេងច្រើនតែគាត់គ្រាន់តែជ្រើសរើសយកឈ្មោះរបស់អ៊ីទៅចឹងគាត់អាចនឹងស្តាប់សំលេងរបស់អ៊ីផ្ទាល់នៅក្នុងនឹងព្រោះនៅខាងសាលាគេនឹងយកសំលេងរបស់អ៊ីនឹងធ្វើការ Upload ចូលនៅក្នុងនឹង ចាស ចឹងអ៊ីអនុញ្ញាតអោយខ្ញុំដើម្បីនឹងធ្វើការសំភាសន៍ដែរឬទេ?

ខៈ សំភាសន៍បានតើក្មួយមានអីដែរ(គាត់អនុញ្ញាតអោយសំភាសន៍)!

ក៖
ចាសអរគុណអ៊ីច្រើនចឹងសំរាប់ថ្ងៃនេះអ៊ី....ជាដំបូងសុំសួរអ៊ីជាបូងសិនតើអ៊ីមានឈ្មោះអីដែរ?

ខ៖ ខ្ញុំឈ្មោះទូច សំណាង!

ក៖ ចាសអ៊ី ហើយចុះអ៊ីមានឈ្មោះពេញឈ្មោះអីដែរអ៊ី?

ខ៖ ឈ្មោះចឹងម៉ងអូន!

ក៖ ចាសអ៊ី ហើយចុះឈ្មោះនេះនឹងអត្តសញ្ញាណប័ណ្ណដែរឬទេ?

ខ៖ ត្រូវអូនត្រូវ!

ក៖ ចាស ហើយអ៊ីមានឈ្មោះហៅក្រៅដែរឬទេ?

ខ៖ អត់ទេអូន មានតែប៉ុន្នឹង!

ក៖ ចុះឈ្មោះនេះតើនរណាជាអ្នកដាក់ឈ្មោះអោយអ៊ី(សំលេងរំខានពីខាងក្រៅ)?

ខ៖ ចាស?

ក៖ តើអ៊ឺ.....

ខ៖ ប៉ាម៉ាកខ្ញុំ!

ក៖ អូ....គាត់ប្រាប់អ៊ីថាឈ្មោះនឹងដាក់មានន័យឬក៏មានអត្ថន័យម៉េចដែរទេ?

ខ៖ អត់ដឹងដែរ(សើច)!

ក៖ (សើច)ចាសអ៊ី!

ខ៖ ដាក់អោយតែបានទេ(សំលេងរំខានពីខាងក្រៅ)!

គ៖ ដាក់ៗអោយតែបាននឹង(សំលេងមនុស្សស្រីពីខាងក្រៅ)!

ខ៖ ចាសអូន!

ក៖ ចាសសព្វថ្ងៃអ៊ីមានអាយុប៉ុន្មានហើយអ៊ី?

ខ៖ (សំលេងកណ្ដឹងពោទ៏) ៥៣!

ក៖ ចាសអ៊ីកើតនៅក្នុងឆ្នាំណាដែរ?

ខ៖ អូ! រឿងឆ្នាំខ្ញុំអត់បានចាំទេអូនប៉ុនតែគ្រាន់តែដឹងថាឆ្នាំនឹងអាយុ៥៣!

ក៖ ចាសអ៊ី ហើយអ៊ី.....សំរាប់ថ្ងៃខែឆ្នាំកំណើតរបស់អ៊ីជាខ្មែរយើងដូចជាឆ្នាំជូតឆ្លូវអីក៏អ៊ីអត់ចាំដែរហ៏(សំលេងរំខានពីខាងក្រៅ)?

ខ៖ ចាំៗ!

ក៖ ឆ្នាំអីដែរអ៊ី?

ខ៖ ឆ្នាំមមី!

ក៖ ឆ្នាំមមី?

ខ៖ ចាសអូន!

ក៖ ចាស ហើយទៅដូចថាអ៊ីសព្វថ្ងៃមានមុខរបរជាអីដែរអ៊ី(សំលេងរំខានពីខាងក្រៅ)?

ខ៖ ខ្ញុំលក់បាយកំប៉ិកកំប៉ុកនៅនឹងផ្ទះ(លក់បាយតិចតួចនៅនឹងផ្ទះ)!

ក៖ អ៊ី មានមុខរបរនឹងប៉ុន្មានឆ្នាំហើយ(សំលេងរំខានពីខាងក្រៅ)?

ខ៖ មានអ៊ី.....ចូលម្ភៃឆ្នាំហើយ ម្ភៃឆ្នាំជាងហើយ ចូល២៥ឆ្នាំហើយ!

ក៖ ចាសអ៊ី ចឹងច្រើនមែនទែន!

ខ៖ ចាសៗអូន!

ក៖ ចាសអ៊ី ហើយចុះអ៊ីស្រលាញ់ការងារនឹងឬក៏យ៉ាងណាដែរបានជាធ្វើវា(សំលេងរំខានពីខាងក្រៅ)?

ខ៖ ធ្វើ....ថាស្រលាញ់ក៏ថាបាន ប៉ុន្តែដូចថាវា....យើង.... កាលពីដើមមកយើងមិនបាន អត់បានរៀនមកចឹងណាស់
អត់បានរៀនចឹងយើងមានតែដើរលក់បាយចឹងទៅ(សំលេងរំខានពីខាងក្រៅ)ចិញ្ចឹមៗគ្រួសារចិញ្ចឹមកូនអីចឹងណាស់ មានតែមុខរបរនឹងដើម្បីចិញ្ចឹមគ្រួសារចឹងទៅ(សំលេងពីខាងក្រៅស្តាប់មិនសូវច្បាស់)!

ក៖ ចាសអ៊ី(សំលេងពោទ៍ម៉ូតូ)!

ខ៖ បើយើងកើតមកវាប៉ះចំនឹងជំនាន់អាពតចឹងណាស់ កើតមកបានដូចថាបងអាយុគាត់ទើបនឹង ១២ឆ្នាំ ហើយខ្ញុំថា ១០ឆ្នាំចុះចាស(សំលេងរំខានស្តាប់មិនបាន) ហើយខ្ញុំតាំងពីដើមមកខ្ញុំរៀនបានតិច!

ក៖ ចាសអ៊ី!

ខ៖ ចាសអូន អ៊ីរៀនបានតិចៗបំផុត ខ្ញុំរៀនបានតិចបំផុត (សំលេងរំខានពីខាងក្រៅ) បងខ្ញុំគ្រាន់បានរៀនចេះអក្សរបាពាំងអក្សរអីខ្លះចំណែកខ្ញុំអត់ទេ ខ្ញុំរៀនបានតិច.....

គ៖ គាត់រៀនក្រោយខ្ញុំទេ....(សំលេងមនុស្សស្រីពីខាងក្រៅ)!

ខ៖ ប៉ុន្តែគ្រាន់តែថាខ្ញុំនឹងសរសេរអីអត់កើតទេគ្រាន់តែថាបើខ្ញុំមើលខ្ញុំចាំបើអានអក្សរខ្មែរនឹងទៅបានតែបើពាក្យជ្រៅពេកក៏ខ្ញុំមើលអត់ដាច់ដែរ(សំលេងរំខានពីខាងក្រៅ) គេដាក់ ដូចថាគេដាក់ផ្លាកអីរង្វងៗចឹងខ្ញុំអានដាច់!

ក៖ ចាសអ៊ី!

ខ៖ ចាសអូន!

ក៖ ចុះអ៊ីមានបងប្អូនក្រៅប្រទេសដែរឬទេ?

ខ៖ អត់ទេអូន(សំលេងរំខានពីខាងក្រៅ) ខ្ញុំមានតែពីរនាក់បងប្អូននឹងទេ!

ក៖ ចាសហើយចុះបងរបស់អ៊ីនឹងគាត់មានឈ្មោះអីគេខ្លះដែរអ៊ី?

ខ៖ ចាស?

ក៖ ឈ្មោះបងប្អូនរបស់អ៊ីគាត់ឈ្មោះអីគេខ្លះដែរអ៊ី?

ខ៖ គាត់ឈ្មោះអឺ....(សំលេងស៊ីផ្លេទ្បាន និងសំលេងម៉ូតូ) គាត់ឈ្មោះអឺ....ហូថា!

ក៖ ចាសសុំម្តងទៀតអ៊ី(សំលេងម៉ូតូ)?

ខ៖ ហូថា!

ក៖ ចាសអ៊ី ហើយចុះគាត់ជាស្រីឬក៏ប្រុសដែរអ៊ី?

ខ៖ គាត់ជាប្រុស!

ក៖ ចាសអ៊ី ហើយចុះគាត់មានទីលំនៅសព្វថ្ងៃនៅឯណាដែរ?

ខ៖ នៅអឺ....នេះហ៎ គាត់នៅនឹងបាត់ដំបង!

ក៖ ចឹងយូរៗបានគាត់មកលេងឬក៏អ៊ីទៅលេងគាត់ម្តង(សំលេងរំខានពីខាងក្រៅ)!

ខ៖ អត់ទេគាត់នៅជួយលក់បាយខ្ញុំយូរៗបានទៅផ្ទះម្តង!

ក៖ អូៗ ចាសអ៊ីចុះអ៊ីសព្វថ្ងៃមានទីលំនៅៗឯណាដែរ?

ខ៖ ខ្ញុំនៅនឹងម៉ង បឹងកង!

ក៖ ចាសអ៊ី សុំបញ្ជាក់ទីតាំងដូចជាអឺ....សង្កាត់ ជាអឺ....ខណ្ឌ(សំលេងរំខានពីខាងក្រៅ)!

ខ៖ បឹងកងមួយ សង្កាត់បឹងកងមួយ....

គ៖ ចំការមន(សំលេងអ្នកដទៃ)!

ខ៖ ខណ្ឌចំការមក ហើយផ្លូវទី ៨៨ ផ្ទះ៥៦(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសអ៊ី ហើយអ៊ីមានទីលំនៅស្រុកកំណើតនៅឯណាដែរ?

ខ៖ វត្តភ្នុំ!

គ៖ វត្តភ្នុំដូចតែគ្នានឹង!

ខ៖ ចាសអូន!

ក៖ ចាសអ៊ី ហើយសព្វថ្ងៃអ៊ីនៅមានឪពុកម្តាយគាត់នៅមានព្រះជន្មរស់ដែរឬទេ?

ខ៖ អត់មានទេគាត់ខូចៗអស់ហើយ(សំលេងរំខានពីខាងក្រៅ)!

ក៖ គាត់មានឈ្មោះអីខ្លះទៅអ៊ី?

ខ៖ គាត់អឺ....ឈ្មោះ(សំលេងអត់បាន) ប៉ាខ្ញុំឈ្មោះហូ (សំលេងរំខានពីខាងក្រៅស្តាប់អត់បាន)!

ក៖ មូលហេតុដែរគាត់ស្លាប់នឹងដោយសារអីដែរ?

ខ៖ ប៉ាខ្ញុំស្លាប់ពេលគេជំលៀស(សំលេងរំខានពីខាងក្រៅស្តាប់មិនបានច្បាស់) ហើយអឺ....ម្តាយខ្ញុំគាត់មក....(ស្តាប់មិនបានច្បាស់)គាត់មកស្លាប់នៅក្នុងជំនាន់បារាំង!

ក៖ ដោយសារតែជំងឺន៍អីន៍?

ខ៖ ចាស(សំលេងរំខានពីខាងក្រៅ)!

កៈ ចាសអ៊ី ហើយអឺ....អ៊ីដូចថាកាលពីសម័យមុននឹងមានបងប្អូនស្លាប់នៅក្នុងសម័យពលពតដែរឬទេ?

ខៈ ខ្ញុំអត់មានទេមានតែប៉ាខ្ញុំ(សំលេងមនុស្សនិងសំលេងរំខានពីខាងក្រៅ)!

កៈ បងប្អូនជីដូនមួយឬក៏ជីទួនមួយអីក៏អត់មានដែរន៍អ៊ី?

ខៈ មានៗ(សំលេងមនុស្សក្បែរនោះ) មាន!

កៈ ចាសអ៊ី!

ខៈ ចាសមានច្រើន(សំលេងរំខានពីខាងក្រៅស្ដាប់មិនបានច្បាស់)!

កៈ ចាសអ៊ី!

ខៈ អឺ.....គេវ៉ៃចោលខ្លះស្លាប់ដោយសារតែអត់បាយខ្លះ!

កៈ ចាសៗ ហើយអឺ....កាលនឹងអ៊ីមានអាយុប៉ុន្មានដែរកាលនៅជំនាន់អាពតនឹង?

ខៈ អាយុ១០ឆ្នាំ!

កៈ ១០ឆ្នាំគត់ម៉ង(សំលេងរំខានពីខាងក្រៅ)!

ខៈ ចាស(សំលេងមនុស្សនិយាយគ្នានិងសំលេងរំខានពីខាងក្រៅ)!

កៈ ចាស គេប្រើអ៊ីអោយទៅធ្វើអីខ្លះទៅកាលនឹង?

ខៈ ខ្ញុំហ៎....(សំលេងរំខានពីខាងក្រៅ) គេប្រើអោយលើកដីលើកទំនប់ជីកប្រឡាយ....(សំលេងមនុស្សនិយាយគ្នាពីខាងក្រៅ)!

កៈ អ៊ឹម....

ខៈ ចាសអូនកាលនឹងគេប្រើយើងអោយទៅលើកទំនប់ ជីកប្រឡាយដូចគេនឹងឯងគេហៅអឺ....កងៗ....កុមារជាតិ គេហៅកងកុមារនឹងណាស់!

កៈ ចាសៗ ហើយអ៊ីកាលនឹងគេអោយបរិភោគអាហារប៉ុន្មានពេលដែរ?

ខៈ ពីរពេលអូន (សំលេងរំខានពីខាងក្រៅ) គេអោយពីរពេលព្រឹកមួយពេលថ្ងៃមួយអ៎....ល្ងាចមួយពេល!

ក៖ ចាស ជាបបរឬក៏ជាបាយដែរអ៊ី?

ខ៖ អ៊ី...ដូចថាខែវស្សាចឹងគេអោយញុំបបរ គេថាអត់ៗអង្ករ គេអោយញុំបបរ ដល់ពេលខែច្រូតហើយអីហើយនឹងគេអោយយើងញុំបាយ(សំលេងរំខានពីខាងក្រៅ) ញុំបាយប្រហែលជាបានប៉ុន្មានខែគេអោយញុំបបរទៀតហើយ!

គ៖ បើនិយាយទៅបបររហូតអូនកាក់មួយស្លាបព្រា(សំលេងអ៊ុំស្រីនៅក្បែរនោះ)!

ខ៖ ជួនកាលទៅ(សំលេងរំខានពីខាងក្រៅ) ទីមួយគេអោយហូបមួយឆ្អែតចឹងទៅ ដល់តែបានប៉ុន្មានខែក្រោយចឹងទៅគេថាអ៊ី....អត់មានអង្ករអត់មានអីចឹងទេ ដាំបបរចឹងចែកអោយយើង ចែកចឹងទៅម្នាក់មួយកាប៉ោយគេនឹង ហើយកាកដូចគាត់និយាយចឹងទឹកមួយកាប៉ោយ!

ក៖ ចាសៗ អ៊ឹម....ហើយទៅអីដូចថាមានចិត្តមួយចង់ដាច់ពីអាពតឆាប់ៗដែរឬទេកាលនៅជាក្មេងៗ(សំលេងរំខានពីខាងក្រៅ)?

ខ៖ អ៊ឹម....អូនដូចជាបន់ស្រន់អស់ហើយមិនដឹងថាថ្ងៃណាបានហូបឆ្អែតអត់មាននឹករឿងអីទេនឹកតែថាមិនដឹងថ្ងៃណាបានហូបឆ្អែតទេបើនៅតែចឹង នៅនឹង(សំលេងឆ្កែព្រួស)....

គ៖ ប៉ុន្មានអូនៗខ្វះប៉ុន្មានអូន?(សំលេងអ្នកដទៃ)!

ខ៖ បើយើងនៅតែអញ្ចឹងមិនដឹងថាកាលទើបបានហូបឆ្អែតទេអូន(សំលេងរំខានពីខាងក្រៅ)....

គ៖ ប៉ុន្មានពាន់?(សំលេងមនុស្សស្រី)

ខ៖ ថាចេះតែបន់ស្រន់ទៅណាស់អោយ.....

គ៖ មួយពាន់ប្រាំ(សំលេងមនុស្សស្រីនិយាយគ្នាពីខាងក្រៅ)?

ខ៖ ដូចថាអោយសភាពដូចដើមវិញមានបាយមានអីហូបគ្រប់គ្រាន់ទៅណាស់ មានចិត្តៗនឹកឃើញតែចឹងណាស់នឹកតែថាធ្វើមិចអោយតែមានលុយចាយដូចពីដើមហើយៗអី....កុំអោយវាអត់ដូចចឹងទៀតណាស់តែទោះជានឹកឃើញយ៉ាងម៉េចក៏ដោយក៏មិនហ៊ាននិយាយអោយរបូតពីមាត់នោះទេនឹកឃើញម៉េចក៏ដោយនឹកតែក្នុងពោះទៅបានហើយកាលណាតែ

យើងអត់បានទេណាស់(សំលេងម៉ូតូ)បើនិយាយទៅខ្លាចថាត្រូវគេចាប់បាន(សំលេងស៊ីផ្លេឡាន)!

ក៖ ចាសអ៊ី!

ខ៖ ចាស....

ក៖ ចាសអ៊ីចាស.....

ខ៖
បើកាលណាតែយើងហ៊ាននិយាយពាក្យមិនល្អអីតែគេលឺគេញ្ញុះញង់អោយគេយកយើងទៅវ៉ៃចោលហើយ(សំលេងរំខានពីខាងក្រៅ)ដូចថាវាឃើញយើងមានសំបុល សៗ ចឹងវាយកយើងទៅវ៉ៃចោលហើយវាថាយើងកូននាយទុនសក្តិភូមិចឹងណាស់ចឹងគេថាអោយយើងចឹងណាស់!

ក៖ ចាស!

ខ៖ ហើយយើងចេះតែមិនហ៊ានមាត់មិនហ៊ានករអីនោះទេចេះតែខិតខំធ្វើការនឹងទៅអោយគេដើម្បីកុំអោយគេវ៉ៃយើង....យកយើងទៅវ៉ៃចោល(សំលេងរំខានពីខាងក្រៅ)!

ក៖ អឺម...ជីវិតរបស់អ៊ីនៅពេលនឹងពិបាកមែនទែន....

ខ៖ យី....លំបាកណាស់អូនពីបាកណាស់គ្មានអីពិបាកជាងកាលនៅជំនាក់អាពតនឹងទេពិបាកបំផុតតាំងពីចូលដល់ជំនាន់នឹងមកតាំងពីការហូបចុក
តាំងពីការគេងអីនឹងក៏ពិបាកនិយាយទៅពិបាកសព្វគ្រប់បែបយ៉ាងហ្នឹង(សំលេងរំខានពីខាងក្រៅ)ចេះតែស្រម៉ៃថាហើយ.....ខ្លាចតែគេយកទៅវ៉ៃចោលទេអត់ហ៊ាននិយាយអីទេម្ង៉ៃៗមិនហ៊ាននិយាយអីនោះទេខំតែធ្វើការតែម៉្យាងនឹងមិនហ៊ាននិយាយថាអឺ....(សំលេងរំខានពីខាងក្រៅ)ហៅអី....អឺ....ដូចថាហៅគេសុទ្ធតែមិត្ត មិត្តពូ មិត្តអីចឹងណាស់ ចាស យើងចេះតែខិតខំធ្វើការងារចឹងទៅកុំអោយគេថាអោយយើងហើយធ្វើម៉េចកុំអោយតែគេយកយើងទៅវ៉ៃចោលនឹងទៅ ហើយយើងធ្វើការខុសអីនឹងដូចថាយើងធ្វើការអីយូរៗឬក៏យើងទៅបត់ជើងអីយូរៗក៏មិនបានដែរគេទៅយូរពេកក៏មានគេតាមដានយើងដែរ!

ក៖ (សើច)!

ខ៖ ចាស(សើច) មិនធម្មតាទេណាគេសួរយើងគេកសាងយើងឥលូវហើយ!

ក៖ ចាស ហើយចុះអីកាលនឹងអីមានដែលបានឃើញអាពតយកមនុស្សទៅសំលាប់ចោលនៅនឹងភ្នែកដែរឬទេ?

ខ៖ ចាសខ្ញុំអឺ....កាលនៅនឹងជំនាន់អាពតខ្ញុំនៅតូចដែរទេខ្ញុំមិនឃើញអឺ...អោយនេះទេ(មិនបានឃើញគេសំលាប់មនុស្សផ្ទាល់ទេ)ប៉ុន្តែគ្រាន់តែថាបានឃើញគេហៅទៅ(សំលេងរំខានពីខាងក្រៅ) ប៉ាខ្ញុំអីនឹងក៏ត្រូវគេហៅទៅដែរគេហៅទៅគេថាមិត្តហាមិត្តឯងអឺ....អង្គការហៅទៅរៀនសូត្រពេលនឹងណាស់ពេលដែលគេហៅយើងអោយទៅរៀនសូត្រនឹងណាស់គេយកយើងទៅវ៉ៃចោលហើយនឹង(សំលេងរំខានពីខាងក្រៅ)ហើយក្រុមគ្រួសារយើងនឹងដឹងខ្លួនណាស់ថាគេហៅយើងនឹងយកទៅសំលាប់ហើយតែមិនដឹងថាពួកយើងនឹងបានធ្វើអីខុសនោះទេណាស់គេយកទៅបាញ់ចោលនឹង!

ក៖ អឺម!

ខ៖ ចាស ហើយមានចេះមួយទៀតប៉ារបស់ខ្ញុំគាត់ពីដើមមកគាត់ជាកូនអ្នកធ្វើស្រែធ្វើចំការដែរណាស់ប៉ុន្តែដូចស្រែចំការរបស់គាត់នឹងនៅនឹងបាត់ដំបងនឹងឪពុកគាត់នឹងដូចថាមួយស្រុកមួយភូមិនឹងដូចថាគាត់វាមានគ្រាន់បើជាងគេណាស់(ឪពុករបស់គាត់មានទ្រព្យសម្បត្តិច្រើនជាងគេ) ដល់ហើយទៅមានអ្នកខ្លះគេធ្លាប់ដឹងពីប្រវត្តិរបស់យើងចឹងវាយកទៅវាយការណ៍ហើយពេលវាវាយការណ៍ទៅបណ្តាញគេទៅហើយបណ្តាញគេថាប៉ាខ្ញុំនឹងមិនចេះធ្វើស្រែទេ ដល់ហើយគេថាបើចឹងអ្នកឯងដកអង្គាល់ ដកនាស់អោយអស់ទៅហើយអោយប៉ារបស់ខ្ញុំនឹងដាក់រៀបសារថ្មីដល់ហើយប៉ាខ្ញុំធ្វើបានទាំងអស់(សំលេងរំខានពីខាងក្រៅ) បានគេមិនយកទៅវ៉ៃចោលនឹងគាត់ធ្វើបានទាំងអស់ដល់ពេលធ្វើបានទាំងអស់ដល់ពេលដល់មកលើកក្រោយ(សំលេងរំខានពីខាងក្រៅស្តាប់មិនបានច្បាស់) វាយកឈ្មោះដែលយើងដាក់ធ្វើការម្តងចុះអឺ...នៅពេលដែលយើងទៅចូលធ្វើការគេមិនមានឈ្មោះយើងគេដាក់ឈ្មោះយើងនឹងដាក់យកទៅសំភាសន៍យកអីនឹងណាស់?

ក៖ ចាសៗអឺ!

ខ៖ អឺ....និយាយថាយើងបើនៅក្នុងសម័យនឹងយើងថាយើងសំភាសន៍ចឹងណាស់!

កៈ ចាសៗ(សំលេងរំខានពីខាងក្រៅ)!

ខៈ
ដល់ហើយវាលើកមកថានេះឈ្មោះរបស់(ស្តាប់មិនបាន)អត់ធ្វើការអីទេនេះធ្វើការងារជាទាហាន(សំលេងរញ៉េរញ៉ៃពីខាងក្រៅ)
ដល់តែចឹងមិនបានប៉ុន្មានក្រោយគេហៅយកទៅរៀនសូត្រទៀតហៅយើងទៅនឹង(សំលេងរំខានពីខាងក្រៅខ្លាំងស្តាប់មិនបាន)!

កៈ គាត់ស៊ើបដឹងចឹងម៉ងឬក៏ដឹងមកពី....

ខៈ ចាសគេស៊ើបដឹងម៉ង!

កៈ គាត់ប្រាប់យើងរបៀបជាក់ស្តែងម៉ង!

ខៈ ដូចថាយើងធ្លាប់ធ្វើជាកសិករធ្វើការងារអីក៏ដោយកាលពីសង្គមចាស់ណាស់អាន្នឹងគេហៅថាពីសង្គមចាស់ហើយកាលណាយើងនៅក្នុងស្រុកភ្នំពេលចេះគេជំលៀសយើងទៅ(សំលេងរំខានពីខាងក្រៅ)
នៅស្រុកឆ្ងាយចឹងអានឹងគេថាយើងពួក១៧មេសាហើយនឹងណាស់!

កៈ អឺម....

ខៈ គេមិនដែលហៅពួកយើងថាពួកអ្នកចាស់ទេ គេហៅតែយើងថាពួក១៧មេសាទេអ្នកក្រលំបាកលំបិនដើរសុំទានគេដើរបុលគេពីដើមមកអានឹងបានគេថាៗ....អានឹងអ្នកក្រពិតប្រាកដហើយបើយើងធ្វើការអីនឹង
យើងមានមុខរបរអីធំដុំអានឹងគេហៅយើងថាពួកនាយទុនសក្តិភូមិហើយអានឹងសំរាប់អ្នកធ្វើការណាស់.....

គៈ ពួកសក្តិភូមិ....

ខៈ បើអ្នកគេធ្វើការអានឹងវាហៅថាអ្នកនឹងអ្នកក្បត់ជាតិហើយ!

កៈ អូ....ហៅចឹងម៉ង!

ខៈ ធូន់ៗណាស់អូន
ប៉ាខ្ញុំហៅទៅគេថាគាត់នឹងកូនកាត់ដល់ហើយគាត់ថាតែគាត់ទៅនឹងដឹងតែចប់ហើយ!

កៈ ចុះគាត់មានបានផ្តែផ្តាំអីដល់កូនចៅដែរទេអឺ?

ខ៖ អត់ៗទេ(សំលេងរំខានពីខាងក្រៅ) មិនបាន គ្រាន់តែបែរងាកៗមិនហ៊ាននឹងមាត់ករអីផង(គ្រាន់តែងាកសំលឹងមើលកូនតែមិនហ៊ាននិយាយអ្វី)!

ក៖ ហើយចុះគាត់កាលនឹងដូចថាគេហៅទៅគាត់ត្រូវទៅភ្លាមគេអត់មានទុកពេលអោយយើងនិយាយជាមួយគ្រួសារទេហ៍?

ខ៖ គេអត់មានទុកពេលអីអោយយើងទេដល់ពេលគេយកយើងទៅតែម្តង!

ក៖ អូ!

ខ៖ ហើយដឹងតែថាគេយកទៅហើយជីវិតដឹងតែចប់ហើយ!

គ៖ ដឹងហើយប៉ុន្តែយើងមិនហ៊ានមាត់មិនហ៊ានករទេប្រពន្ធកូននោះកូនចៅអីនឹងគ្មានហ៊ានមាត់គ្មានហ៊ានករ អីទេ(សំលេងរំខានពីខាងក្រៅ)!

ខ៖ អត់ហ៊ានមាត់ចឹងម៉ង!

ក៖ ហើយចុះអ៊ីពេលដែលគេហៅគាត់ទៅនឹងគេមកហៅពេលព្រឹក ពេលថ្ងៃ ឬក៏ពេលណាដែល?

ខ៖ គេមកហៅនៅពេលល្ងាច!

ក៖ ពេលរៀបល្ងាច(សំលេងរំខានពីខាងក្រៅ)?

ខ៖ ដឹងតែថានៅពេលល្ងាចតែមិនដឹងថានៅម៉ោងប៉ុន្មានដឹងតែថារៀងល្ងាច!

ក៖ ហើយចឹងកាលនឹងដូចថាអ៊ីទើបតែមានអាយុ១០ឆ្នាំចឹង!

ខ៖ ទើបនឹងអាយុ១០ឆ្នាំ(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសហើយនៅពេលនឹងអ៊ីមានអារម្មណ៍យ៉ាងណាដែរនៅពេលដែលហៅឪពុករបស់អ៊ីទៅចឹងណាស់?

ខ៖ ខ្ញុំអាឡើយទៅកងអាឡើយតែទៅកងនឹង(គាត់រវល់ធ្វើការនៅឯកង)ហើយអឺ....មកដល់ម៉ែគាត់ប្រាប់ថាគេហៅគាត់ទៅបាត់ហើយនឹង!

កៈ
អឺម....ចឹងមានន័យថាកាលនឹងក្រុមគ្រួសាររបស់អីកាលនឹងរស់នៅជុំគ្នាអត់នៅបែកគ្នានោះទេ?

ខៈ នៅកាលម្ញឹក៧៦(ក្នុងកំឡុងឆ្នាំ១៩៧៦) ជិតៗចូល៧៧(ជិតចូលឆ្នាំ១៩៧៧) និយាយទៅនៅក្នុងចុងឆ្នាំ៧៦(ចុងឆ្នាំ១៩៧៦)(សំលេងរំខានពីខាងក្រៅ) ៧៥ ៧៦ អឺ...ថាក្នុងឆ្នាំ៧៦ចុះ(គិតត្រឹមឆ្នាំ១៩៧៦) អឺ....ដើមឆ្នាំ៧៦(នៅដើមឆ្នាំ១៩៧៦) នៅចុងឆ្នាំ៧៧នឹង(ចុងឆ្នាំ១៩៧៧) គេបិទស្រាវជ្រាវនឹង(សំលេងរំខានពីខាងក្រៅ) ហើយទៅយើងធ្វើការតាំងពីដើមមកធ្វើការជាទាហាននឹងណាស់!

កៈ ចាសៗ ហើយចុះអ៊ីដូចថាអ៊ីកាលនៅសម័យនឹងអ៊ីបានល្មើសទៅនឹងបទបញ្ជារឬក៏ធ្វើអីដែលធ្វើអោយគេនឹងចាប់កំហុសរបស់អ៊ីធ្ងន់ធ្ងរដែរឬទេ?

ខៈ ខ្ញុំអត់មានទេអត់ហ៊ាន ប្រើ....គេប្រើអោយយើងធ្វើអីយើងធ្វើនឹងទៅគេប្រើអោយយើងធ្វើអីយើងត្រូវធ្វើនឹងព្រោះអីម្ដាយរបស់ខ្ញុំគាត់បានផ្ដែផ្ដាំមកកូនៗថាបើគេប្រើអោយធ្វើអីយើងធ្វើនឹងទៅកុំជំទាស់សម័យនេះណាស់កូនត្រូវចេះអត់ធន់គេប្រើធ្វើអីធ្វើនឹងទៅកូនកុំមាត់(សំលេងរំខានពីខាងក្រៅ)គេប្រើធ្វើអីយើងធ្វើនឹងគេយកទៅបំបែកទៅតាមកងចល័តឆ្ងាយពីម៉ែឪមិនហ៊ានមាត់ទេសុខចិត្តដេកស្រក់ទឹកភ្នែកនៅពេល
យំឡើងមិនហ៊ានមាត់កអីទេធ្វើម៉េចអោយតែជីវិតបានរស់ហើយអោយបានគេងអោយបានហូបឆ្អែត(សំលេងរំខានពីខាងក្រៅ)គ្មានចង់បានអ្វីទាំងអស់កាលនឹងណាស់
ហើយខ្ញុំលឺសួរគេកាលជំនាន់អាពតគេថាអឺ....មិនចេះតមាត់នឹងគេខ្លះទៅ(ស្ដាប់មិនច្បាស់មានសំលេងរំខានពីខាងក្រៅ) គេហ៊ានតវ៉ាតែបើប៉ាខ្ញុំគាត់អត់ហ៊ានតមាត់ត ក នឹងគេទេ!

កៈ ចាសអ៊ី ខ្លាចថាជាមុខសញ្ញារបស់គេ!

ខៈ អឺ...ខ្លាចថាចឹងខ្លាចបំផុតចឹងម៉ង ភ័យព្រួយពិបាកចិត្តណាស់ហើយសុំច្បាប់គេពេលដែលយើងចង់មកលេងផ្ទះនឹងណាស់បើគេអោយមកបានយើងហ៊ានមកបើគេមិនអោយមកទេយើងមិនហ៊ានមកទេអត់ហ៊ានមកទេ
អត់ហ៊ានមកចឹងម៉ងហើយបើវាឃើញយើងសៗចឹង(អ្នកមានសំបុលស)
កាលពីនៅក្មេងៗយើងមានសំបុលស

ហើយសាច់ទ្រលូៗចឹងណាស់(មានសាច់ទ្រលុកទ្រលុន)
កាលមិនទាន់អត់បាយណាស់ដូចថាយើងជាកូនមេជនសក្តិភូមិនភ័យណាស់អូនហើយគ្នាប៊ុនៗឯងនឹងគ្នាឃើញគេចឹងភ័យឡើងញាក់សាច់អស់ហើយទាំងយើងទាំងគេនឹង(សំលេងមនុស្សស្រីនិយាយពីខាងក្រៅ) !

កៈ ចាសត្រូវហើយកាលនឹង!

ខៈ ចាសអូន!

កៈ ហើយចុះគេមានដែលធ្លាប់បានធ្វើបាបអីដែរឬទេ?

ខៈ
យី....មានធ្លាប់ត្រូវបានគេថាអោយដែរតើមានគេធ្លាប់ថាយើងចេះថាយើងចុះ(សំលេងរំខានពីខាងក្រៅ)
ដូចថានៅពេលដែលយើងធ្វើស្រែធ្វើអីនឹងវាថាអោយយើងថាយើងនឹងធ្វើម៉េចនឹងដូចគេបើយើងធ្លាប់ជាកូនសក្តិភូមិមិនធ្លាប់ធ្វើស្រែចំការដូចវាកូនអ្នកកសិករនោះវានិយាយដៀមដាមថាអោយយើងចឹងណាស់(សំលេងមនុស្សស្រីពីខាងក្រៅ)ប៉ុន្តែយើងវាអត់មានមាត់ក
អីណាស់យើងចេះតែនៅស្ងៀមទៅយើងនៅម្នាក់ឯងអឺ...គាត់ថាអីក៏ថាទៅៗខ្ញុំនៅតែស្ងៀមអត់ហ៊ានមាត់កអីទេ(សើច) (សំលេងរំខានពីខាងក្រៅ)ព្រោះខ្លាច!

កៈ ចាសត្រូវហើយអីព្រោះអីកាលនៅសម័យនឹងម្នាក់ៗគឺថាខ្លាចមែនទែន....

ខៈ ខ្លាចណាស់អូនខ្លាចឡើងរួញខ្លួនម៉ង(សំលេងរំខានពីខាងក្រៅ)
សូម្បីតែយើងកំពុងធ្វើការងារនឹងមិត្តបងខ្ញុំសុំទៅបត់ជើង
អឺមទៅៗទៅរួតមកវិញមក(ពេលទៅត្រូវប្រញាប់ត្រឡប់មកវិញ)ទៅអោយលឿនត្រូវឆាប់មកត្រឡប់មកវិញណាស់មិត្តឯងគេសំលក់យើងហើយសំលុតទៀត
ហើយបើយើងឈឺកោសខ្យល់អីចឹងយើងទៅសុំគេឈប់សំរាកមួយថ្ងៃនឹងណាស់
គេថាចឹងហើយកូននាយទុនសក្តិភូមិមិនដែលធ្វើការងារចឹងណាស់ដល់តែពេលមកធ្វើការងាប៉ុន្នឹងៗវាហត់វានឿយហើយបានជាងាកខ្យល់ៗនឹងនោះ
ខ្យល់នឹងខ្យល់សតិអារម្មណ៍នឹងមិត្តឯង(សំលេងរំខានពីខាងក្រៅ)
អត់ទេណាវាថាអោយយើងចឹងម៉ងណាស់ហើយយើងមិនហ៊ានតមាត់នឹងគេ(មិនហ៊ានតវ៉ាថាអោយគេវិញ)!

កៈ ត្រូវហើយចាស!

ខៈ យើងមិននឹងហ៊ានតវ៉ាអីជាមួយនឹងគេ!

កៈ ចាស ហើយចុះកាលនឹងអី ធ្លាប់ឈឺអីគេខ្លះកាលសម័យនឹង?

ខៈ ធ្លាប់នៅកាលក្មេងៗធ្លាប់តែកោសខ្យល់នឹងពេលដែលឈឺកោសខ្យល់ចឹងទៅពេលដែលយើងគ្រុនញាក់ចឹងណាស់ជួនកាលទៅយើងអត់បានបាយចឹងទៅយើងដូចថាខ្សត់ខ្សោយនៅក្នុងខ្លួនចឹងណាស់(សំលេងរញ៉េរញ៉ៃរំខានពីខាងក្រៅ) ហើយចេះតែ....ទៅធ្វើការងារចឹងដូចថាយើងល្វើយចឹងដើរមិនចង់រួចទេអូននិយាយរួមវាមិនអោយយើងញុំម៉ងណាស់វាតាំងពីអំបិលតាំងពីប្រហុកតាំងពីអីឡើងវាមិនអោយយើងញុំទេ(សំលេងរំខានខ្លាំងពីខាងក្រៅ) វាអោយយើងស្គាល់បើថាវាស្លប្រហុកចឹងណាស់ស្លម្ជូរក៏ដោយស្លអីក៏ដោយវាមិនដែលដាក់ធុំក្លិនប្រហុកដូចជាយើងទេអូន ធុំលេវៗនឹងហើយទឹកឡើងខ្មៅជួនកាលនឹងក៏បបរទៅ ហើយបើបាយខ្ញុំញុំវិញណាស់បាយលាយត្រកួនចឹងទៅខ្ញុំធ្លាប់ហូបអស់ហើយបាយលាយគល់ចេក បាយលាយពោតក្រហម គល់ល្ហុងខ្ញុំធ្លាប់អស់ហើយ(សំលេងរំខានពីខាងក្រៅ) ឆ្លងកាត់មកអស់ហើយធ្លាប់ឆ្លងកាត់សព្វបែបសព្វយ៉ាងនឹង!

កៈ ចាស កាលសម័យនឹងតើអីមានដែលបានចងចាំអ្វីជាងគេដែលធ្វើអោយតាំងពីនឹងរហូតមកដល់ឥលូវនឹងអីមិនដែលបំភ្លេចបានណាស់ដូចថាទិដ្ឋភាពតាំងពីនឹងរហូតមកដល់ឥលូវនឹងណាស់?

ខៈ ខ្ញុំមិនដែល....ខ្ញុំអាចបំភ្លេចបានទេកាលជំនាន់អាពតចង់និយាយចឹងខ្ញុំមិនអាចនឹងបំភ្លេចបានទោះជាយ៉ាងណាក៏ដោយខ្ញុំចងចាំរហូតមកហើយហេតុបានជាថាមិនអាចនឹងបំភ្លេចបានមិនថាយើងបានមើលតាមរយៈនៅក្នុងសាច់រឿងនៅក្នុងទូរទស្សន៍ក៏ដោយ....(សំលេងរំខានពីខាងក្រៅ)អូនឯងមើលទៅឃើញហើយឃើញអាទិដ្ឋភាពដែលពួកវាបានធ្វើដាក់មកលើពួកយើងហើយមិនខុសគ្នាទេ មិនខុសពីគ្នាទេ!

កៈ ចាសអ៊ី!

ខៈ ចាស ចុះអូនឯងមើលមួយថ្ងៃៗភ័យព្រួយចង់ងាប់ភ័យខ្លាចថាបើធ្វើការងារខុសគេយកក៏សាងយកទៅរៀនសូត្រខ្លាចគេមិនអោយបាយញុំ

កាលជំនាន់នឹងមិនហ៊ានទាំងនិយាយពាក្យថាញុំផងគេហៅថាហូប ភ័យមិនដឹងថាងាប់(ស្លាប់)ថ្ងៃណាអីថ្ងៃណានោះទេបើអត់បាយដើរចឹងពីនេះទៅថ្មល់ដើរមិនចង់រួចផងនឹង!

កៈ ត្រូវហើយចាសអ៊ី!

ខៈ ចាសអូន!

កៈ កាលនឹងអត់បាយគឺពិបាកទ្រាំណាស់!

ខៈ
ហើយយើងអឺ....យើងទៅធ្វើស្រែធ្វើចំការនឹងទៅធ្វើស្រែចំការដកស្ទូងអីនឹងណាស់តិចថាយើងទៅចាប់ក្តាមអីបានយើងយកមកបុកហូបអីម្នាក់ឯងនឹងគេមិនអោយយើងបុកទេ(គេមិនអោយបុកក្តាមហូប) គេមិនអោយយើងយកមកធ្វើអីទេ(គេមិនអោយយកមកធ្វើជាម្ហូបសំរាប់ញុំទេ) ដាក់រួមគេអោយយើងយកមកដាក់រួមចឹងម៉ង!

កៈ អូ....ចាស!

ខៈ គេថាមិត្តឯងដាក់រួមទៅ
មិនអោយធ្វើជាអឺ....ជារបស់ឯកជនខ្លួនឯងអីទេ(សំលេងរំខានពីខាងក្រៅ)!

កៈ ចាស យកទៅដាក់នៅក្នុងសហាករណ៏ម៉ង?

ខៈ ចាសយកទៅដាក់នៅក្នុងសហាករណ៏ម៉ង!

កៈ ចាស!

ខៈ យកទៅដាក់នៅកន្លែងការដ្ឋានបាយទៅ (សំលេងរំខានពីខាងក្រៅ)
គេមិនអោយយើងមកហូបអីតែម្នាក់ឯងទេ
ហើយមកហូបនឹងយើងវាមិនសូវដូចថាវាមិនដឹងរសជាតិទៅណាទេអូនមិនដឹងសាប់មិនប្រៃទេ
អូនធ្វើនឹងជូនកាលគ្មាននឹងអំបិលដាក់ផង
បើយើងធ្វើនឹងមានអំបិលមកពីណាទាល់តែយើងទៅសុំអំបិលមកពីគេ!

កៈ គេអោយដែរហ៎អ៊ី?

ខៈ
បើយើងធ្វើទាល់តែយើងនឹងទៅសុំអំបិលពីគេមក(បើសិនជាគាត់ចង់ធ្វើម្ហូបគាត់ត្រូវទៅសុំអំបិលពីកន្លែងការដ្ឋានបាយ) ជួនកាលបានជួនកាលអត់ចឹងទៅ

ទំម្រាំតែនឹងបាននឹងគេថាអោយ(គេស្តីអោយ) ម៉េចមិត្តឯងយកទៅធ្វើអីគេ? បានក្តាមបានខ្យងម៉េចមិនយកទៅដាក់ជារបស់រួមទៅ ចឹងណាស់អូន!

ក៖ ចាសៗអ៊ី!

ខ៖ គេថាអោយយើងចឹងណាស់(សំលេងរំខានពីខាងក្រៅ)!

ក៖ ចុះពេលដែលនៅក្នុងសម័យអ៊ីដែលបានឆ្លងកាត់កាលនៅជំនាន់អាពតហើយកាលដែលនៅក្នុងសម័យក្រោយអាពតនឹងថាតើអ៊ីមានការតស៊ូមានការលំបាកអីគេខ្លះនៅក្នុងជីវិតរបស់អ៊ីដែរ?

ខ៖ តស៊ូនៅក្នុងជីវិតរបស់អ៊ី(គាត់អស់សំណើច) ការតស៊ូនៅក្នុងជីវិតរបស់ខ្ញុំគឺ....នេះអ៊ី...ខ្ញុំមកនៅនឹងភ្នំពេញមកលក់ដូរមកលក់បាយលក់សំលរអញ្ចឹងទៅ (សំលេងរំខានពីខាងក្រៅ) សន្សំលុយទៅបានទិញផ្ទះនៅចឹងទៅណាស់អូន ចូលមកទៅបានមកពីស្រុកនឹងបានពីរនាក់នឹងជាមួយនឹងគាត់នេះចាស
មកទៅហើយនៅផ្ទះជាមួយនឹងម្តាយមីងចឹងទៅហើយម្តាយមីងគាត់អើយយើងនៅជាមួយទៅហើយគាត់អោយនៅជាមួយចឹងទៅហើយយើងរកលុយបានទៅយើងសន្សំបានទិញផ្ទះនៅចឹងណាស់!

ក៖ ចាសអ៊ី!

ខ៖ ចាសហើយក្រោយមកយើងក៏មានគ្រួសារយើងទៅយើងមានមុខរបរចឹងទៅហើយចាប់មុខរបរនឹងលក់ដូរតាំងពីនឹងរហូតមកដល់សព្វថ្ងៃនឹងណាស់អូន!

ក៖ ចាសអ៊ី ហើយកាលនឹងអ៊ីមានរកមុខរបរអីផ្សេងដែរឬទេឬក៏មានតែមុខរបរតែមួយនឹងទេ?

ខ៖ (សំលេងរំខានពីខាងក្រៅ) ខ្ញុំមុនដំបូងខ្ញុំលក់បាយកញ្ចប់ពេលដែលខ្ញុំមកនៅជាមួយនឹងម្តាយមីងសំបូងខ្ញុំលក់បាយកញ្ចប់បាយខ្ចប់ស្លឹកឈូកយើងនឹងណាស់!

ក៖ ខ្ចប់ស្លឹកឈូក?

ខ៖ ចាស ខ្ចប់ស្លឹកឈូកនឹង!

ក៖ ជាមួយនឹងមុខម្ហូបខ្មែរយើងនឹង?

ខ៖ អត់ទេលក់តែបាយកញ្ចប់ទេកាលនឹងក្នុងកំឡុងឆ្នាំ៧០ជាងនឹងលក់តែបាយកញ្ចប់ទេ!

ក៖ អីលក់នៅឯណាដែរ?

ខ៖ នៅអូឬស្សី!

ក៖ អូ....លក់នៅក្នុងផ្សារម៉ង?

ខ៖ ចាស ដល់ពេលលក់ចឹងទៅហើយទៅដល់ពេលបានសន្សំលុយនឹងហើយយើងរស់នៅនឹងទៅរួចហើយទើបបានសន្សំលុយបានហើយបានទិញផ្ទះនៅខ្លួនឯងនឹងហើយចុងក្រោយមកយើងបង្កើតបានជាក្រុមគ្រួសារមកនឹងហើយក៏បង្កើតជាមុខរបរលក់បាយស្រូបលក់បបរចឹងទៅទុកគ្រាន់សំរាប់ចិញ្ចឹមកូនចិញ្ចឹមអីចឹងទៅណាស់អូន!

ក៖ ចាសអ៊ី ហើយកាលនៅក្នុងជំនាន់នឹងដែរអ៊ីអាចរកក្នុងមួយថ្ងៃលក់បានមួយថ្ងៃនឹងប៉ុន្មានដែរអ៊ី?

ខ៖ (សំលេងរំខានពីខាងក្រៅ) អូនអើយកាលនឹងដូចថានៅពេលដែលយើងលីវចឹងយើងរកបានច្រើនចឹងទៅណាស់ហើយខ្ញុំរកលុយបានចឹងខ្ញុំយកទៅអោយម៉ែចឹងទៅណាស់ហើយជូនកាលនឹងក៏ទុកសន្សំខ្លះទៅ ខ្ញុំមិនដឹងថាក្នុងមួយថ្ងៃនឹងយើងរកបានប៉ុន្មាននោះទេដូចថាយើងមកពីស្រុកបាត់ដៃទទេរចឹងណាស់អូន!

ក៖ ចាសអ៊ី!

ខ៖ ហើយដល់ពេលតែមកដល់នឹងយើងចេះតែសន្សំលុយបានទិញផ្ទះទិញអីបាននៅចឹងទៅ(សំលេងរំខានពីខាងក្រៅ) ចឹងទៅដល់រហូតមកដល់សព្វថ្ងៃនឹងទៅណាស់!

ក៖ ចាស!

ខ៖ ចាស ហើយខ្ញុំក៏មិនភ្លេចគុណបុណ្យរបស់ម្តាយមីងរបស់ខ្ញុំដែរនៅពេលដែលខ្ញុំមកនឹងគឺមកដោយដៃទទេរហើយមករស់នៅជាមួយគាត់នឹងណាស់ ហើយទៅមករស់នៅចឹងទៅបានសន្សំលុយសន្សំអីទិញផ្ទះទិញអីនៅចឹងទៅមានក្រុមគ្រួសារទាំងអស់គ្នាចឹងទៅ!

កៈ ចាសអ៊ី ហើយមុខរបរនេះជាធម្មតាអ៊ីអាចនឹងរកប្រាក់ចំណូលបានប៉ុន្មានដែរអត់ទាន់បានដកថ្លៃចំណាយអីគិតតែទៅលើចំណូលណាស់អ៊ី?

ខៈ (សំលេងរំខានពីខាងក្រៅ) បាន៧០ម៉ឺនទៅ៨០ម៉ឺនចឹងទៅណាស់អូន!

កៈ ក្នុងមួយថ្ងៃន៍អ៊ី?

ខៈ ចាស បានបងប្អូនកូនចៅខ្លួនឯងនឹងមកជួយលក់ជួយដូរនឹង(សំលេងរំខានពីខាងក្រៅ) យើងមិនមានជាជីវភាពមុខរបរអីអោយវាធំដុំអីណាទេអូនល្មមតែយើងដូចថាយើងដោះស្រាយបាននៅក្នុងជីវភាពគ្រួសារយើងបានចឹងណាស់ហូបចុកអោយរៀនសូត្រអីចឹងទៅណាស់!

កៈ ចាសអ៊ី!

ខៈ ចាស (សំលេងរំខានពីខាងក្រៅ)!

កៈ ចុះអ៊ីនៅពេលថ្ងៃអនាគតទៅអ៊ីមានចង់ធ្វើអីបន្ថែមឬក៏មានគំរោងអីបន្ថែមសំរាប់ទៅនឹងអាជីវកម្មមួយនឹងដែរជារបស់អ៊ីដែរឬទេ?

ខៈ (សំលេងរំខានពីខាងក្រៅ) ខ្ញុំដូចជាអត់មានអី....(សំលេងរំខានពីខាងក្រៅ) អត់មានទេអូនឥលូវនឹងនោះយើងគ្រាន់តែបានចិញ្ចឹមកូននឹងអោយកូនបានរៀនសូត្របានអោយកូនបានរៀនសូត្រ
បានអោយចប់ទៅមានការងារធ្វើទៅយើងមិនបានមានអ្វីនឹងជួយគាត់ទេមានតែគាត់ពួកគាត់បានរៀនសូត្រនឹងទៅអោយបានតែពួកគាត់នឹងមានការងារធ្វើនឹងទៅគឺថាវាល្អណាស់ទៅហើយ(សំលេងរំខានពីខាងក្រៅ)!

កៈ ចាសៗអ៊ី!

ខៈ ឥលូវនឹងជង្គង់ខ្ញុំនឹងដូចជាអូនឯងបានឃើញចឹង
សព្វថ្ងៃនឹងជង្គង់របស់ខ្ញុំនឹងក៏វាឈឺផងអីផងនឹង(សំលេងរំខានពីខាងក្រៅ)
ហើយម៉្យាងទៀតដូចថាមិនទាន់ដឹងថាគិតអីអោយវែងឆ្ងាយនោះទេប៉ុន្តែគ្រាន់តែថាមុខរបរមួយយើងអាចអោយយើងនឹងចិញ្ចឹមកូនបានអាចអោយកូនរៀនសូត្របានអីចឹង!

កៈ ចាសអ៊ី!

ខៈ ធ្វើម៉េចអោយតែពួកគាត់បានរៀនសូត្រនឹងទៅ!

កៈ អឺម....(សំលេងរំខានពីខាងក្រៅ)
ចាសហើយអ៊ីសព្វថ្ងៃនឹងមានជំងឺឬក៏ឈឺអីគេដែរនៅក្នុងខ្លួននឹង?

ខៈ (សំលេងរំខានពីខាងក្រៅ) ខ្ញុំឈឺដូចថាវះអីគេដូចថាខ្ញុំបានវះក្រលៀនអីចឹងទៅណាស់អូន!

កៈ អឺម.....ចាស
ហើយអ៊ីអឺ....របៀបថាបទពិសោធន៍របស់អ៊ីល្អៗរបស់អ៊ីតាំងពីមុននឹងរហូតមកដល់តល្ងូវនឹងដែលអ៊ីនឹកឃើញហើយធ្វើអោយអ៊ីសប្បាយចិត្តណាស់អ៊ីៗមានដែរឬទេ?

ខៈ បទពិសោធន៍កាលពីអាពតហ្អែស?

កៈ ចាសបទពិសោធន៍ល្អៗដែលមាននៅក្នុងជីវិតរបស់អ៊ីណាស់(សំលេងរំខានពីខាងក្រៅ)

ខៈ
បទពិសោធន៍ល្អៗអឺ.....ដូចខ្ញុំបានប្រាប់អូនឯងរួចមកហើយនឹងគឺដូចថាខ្ញុំមានមុខរបរលក់បាយលក់អីចឹងទៅខ្ញុំមកនឹងលក់បាយលក់អីចឹងទៅ(សំលេងរំខានពីខាងក្រៅ)
ហើយទៅខ្ញុំតាំងពីពេលដែលមានគ្រួសារនឹងមកខ្ញុំមានមុខរបរលក់បាយលក់អីនឹងគឺថាខ្ញុំអាចរកលុយសំរាប់ចិញ្ចឹមកូនរបស់ខ្ញុំនឹងបានចឹងទៅណាស់អូន(សំលេងរំខានពីខាងក្រៅ)!

កៈ ចាសអ៊ី ចឹងនៅពេលដែលអ៊ីនឹកឃើញមកធ្វើអោយអ៊ីសប្បាយចិត្តម៉ងន៍អ៊ី?

ខៈ
ចាសពេលដែលនឹកឃើញទៅធ្វើអោយខ្ញុំសប្បាយចិត្តទោះបីជាខ្ញុំមិនសប្បាយអីក៏ខ្ញុំ(សំលេងរំខានពីខាងក្រៅ)បានកូនរបស់ខ្ញុំរៀនបានរៀបចប់បានគ្រប់គ្នារៀនចប់បានបីនាក់ហើយនៅសល់ម្នាក់ទៀត!

កៈ ចាសអ៊ី!

ខៈ
ចាសខ្ញុំសប្បាយចិត្តណាស់រាល់ថ្ងៃដូចថាមិនមានអីដែលហៅថាសល់ទេអូនសល់បានត្រឹមតែថាបានតែស៊ីនឹង ចាសខ្ញុំនិយាយត្រង់ម៉ងទៅ!

កៈ ចាសអ៊ីហើយអឺ....អ៊ីមានកូនប៉ុន្មាននាក់ដែរកូនរបស់អ៊ីណាស់អ៊ី?

ខៈ ខ្ញុំមានកូន៤នាក់!

កៈ អ៊ីមានកូនប្រុសប៉ុន្មានស្រីប៉ុន្មាននាក់ដែរអ៊ី?

ខ៖ ខ្ញុំមានកូនប្រុសបី ស្រីមួយ(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសហើយចុះពួកគាត់មានឈ្មោះអីខ្លះទៅអ៊ី?

ខ៖ គាត់អ៊ី....បងគេឈ្មោះ ឈិន រតនា(សំលេងរំខានពីខាងក្រៅ) ហើយដល់តែបន្ទាប់មកទីពីរ ឈិត រដ្ឋា បន្ទាប់មកទៀតទីបីឈ្មោះ ឈិត រតនៈ បន្ទាប់មកទៀតកូនទីបួនស្រីនឹងឈ្មោះ ឈិត សុផាត់ណារី!

ក៖ ចាសអ៊ីហើយចុះពួកគាត់រៀបអាពាហ៏ពិពាហ៍រួចហើយអ៊ី?

ខ៖
គាត់....បងគេនឹងបងប្រុសនឹងកូនបង.....កូនអាប្រុសគេនឹងបានរៀបអាពាហ៏ពិពាហ៍បានមួយហើយ!

ក៖ អ៊ឹម....ចាសហើយចុះ....

ខ៖ នៅបីនាក់ទៀតមិនទាន់មានគ្រួសារទេ!

ក៖ ចាសៗអ៊ី
ហើយពួកគាត់មានការងារធ្វើអស់ហើយមែនទេអ៊ីកូនរបស់អ៊ីទាំងបួននាក់នឹងណាស់?

ខ៖ កូនខ្ញុំមានការងារនឹងមានតែបីនាក់ទេ
ចំណែកកូនពៅកំពុងតែរៀន(សំលេងរំខានពីខាងក្រៅ) !

ក៖ ចាស ហើយចុះកូនអ៊ីនឹងគាត់រៀនដល់ថ្នាក់ទីប៉ុន្មានដែរអ៊ី?

ខ៖ (សំលេងរំខានពីខាងក្រៅ) កូនខ្ញុំកូនពៅនឹងរៀនឆ្នាំទីមួយហើយ!

ក៖ អូ....ជានិស្សិតឆ្នាំទីមួយ?

ខ៖ ចាសៗអូន!

ក៖
ចាសហើយចុះកូនរបស់អ៊ីបីនាក់ទៀតគាត់ធ្វើការខាងផ្នែកអីដែរឬមួយក៏មានធ្វើការរដ្ឋដែរឬទេ?

ខ៖ កំពុងធ្វើការ...(សំលេងរំខានពីខាងក្រៅ) ចាសៗ(កូនរបស់គាត់បីនាក់ធ្វើការងាររដ្ឋ)!

កៈ
ចាសហើយអ៊ី.....អ៊ីទាក់ទងជាមួយនឹងដូចថាបទពិសោធន៍នៅក្នុងជីវិតរបស់អ៊ីដែលលំបាកជាងគេបំផុតដែលអ៊ីនឹកឃើញហើយធ្វើអោយអ៊ីពិបាកចិត្តនឹងតើអ៊ីមានដែរឬទេ?

ខៈ ពីមុនមកចេះតែពិបាកហើយអូន
ចេះតែនឹកឃើញថាយើងមានប្អូននាក់ហើយចេះតែនឹកឃើញថាខ្ញុំរកតែម្នាក់ឯងចឹងណាស់ដូចថាខ្ញុំភ័យណាស់ខ្ញុំភ័យខ្ញុំខ្លាចថាមិនដឹងថាអាចចិញ្ចឹមគេអោយបានរៀនចប់ហើយរឿងការងារអីចឹងណាស់ហើយខ្ញុំនឹកឃើញឡើងចេះតែភ័យចេះតែបារម្ភចឹងទៅខ្លាចថាមិនមានលទ្ធភាពអោយកូននឹងរៀនបានចប់ចុងចប់ដើម!

កៈ ចាសអ៊ី!

ខៈ
ដល់តែឥលូវនឹងកូនបងបីនាក់នឹងគេបានរៀនចប់អស់ហើយៗគេក៏មានការងារធ្វើដែរហើយយើងក៏សប្បាយចិត្តដែរដែលកូនមានការងារធ្វើចឹងណាស់ហើយរៀនក៏បានចប់ចឹងណាស់!

កៈ ចាសអ៊ី!

ខៈ ចាសអូន!

កៈ ចាសហើយចុះអីរៀបការនៅក្នុងឆ្នាំណាដែរអ៊ី?

ខៈ ខ្ញុំហ៎? ខ្ញុំដូចថារៀបការនៅក្នុងកំឡុងឆ្នាំកៅជាង
បើថានៅក្នុងឆ្នាំណានោះខ្ញុំអត់បានចាំនោះទេ
ខ្ញុំភ្លេចអស់ហើយដូចថាខ្ញុំអត់បានគិតនេះ...ដូចថាខ្ញុំអត់បានគិតដែរចឹងណាស់ដូចកាលនឹងវាវល់វក់ពេក!

កៈ ចាសអ៊ី!

ខៈ ដូចថាចខ្ញុំមិនដឹងថារៀបការនៅក្នុងឆ្នាំណាអោយប្រាកដនោះទេ
តែដឹងតែថានៅក្នុងកំឡុងឆ្នាំកៅជាងតែមិនដឹងថានៅក្នុងឆ្នាំណាអោយប្រាកដណាស់អូន!

កៈ ចាស
ហើយចុះកាលនឹងពេលដែលអីរៀបការនឹងអ៊ីស្រលាញ់គ្នាឬក៏ឪពុកម្តាយជាអ្នករៀបចំអោយ?

ខៈ ចាស់ៗៗគាត់ជាអ្នករៀបចំអោយ!

កៈ អូ....ចាសអ៊ី ហើយចុះលោកពូដែលត្រូវជាស្វាមីរបស់អ៊ីនឹងគាត់មានឈ្មោះអីដែរអ៊ី?

ខៈ ស្វាមីរបស់អ៊ីគាត់ឈ្មោះ ងឿន សុភិន!

កៈ ចាសអ៊ី ហើយចុះលោកពូគាត់មានស្រុកកំណើតនៅឯណាដែរអ៊ី?

ខៈ ស្រុកកំណើតរបស់គាត់នឹងនៅខេត្ត!

កៈ ចាស?

ខៈ ស្រុកកំណើតរបស់គាត់នៅនឹងក្នុងខេត្តតាកែវ!

កៈ លោកពូមានស្រុកកំណើតនៅក្នុងតាកែវ?

ខៈ ចាសៗអូន!

កៈ ចាសអ៊ី
ចឹងទាល់តែពេលដែលគាត់បានមករៀបការជាមួយនឹងអ៊ីទើបបានអ៊ីហើយនឹងគាត់បានស្គាល់គាត់ចឹងម៉ងហ្អែស?

ខៈ ចាសៗអូន!

កៈ ហើយអ៊ី.....ដូចថាកាលសម័យមុននឹងពីពេលដែលអ៊ីនៅពីតូច
កាលអ៊ីពេលដែលអ៊ីនៅតូចៗវិញណាស់ខ្ញុំសួរបកទៅកាលនឹងវិញ
អ៊ីមានដែលមានក្តីស្រម៉ៃថានៅដែលធំឡើងមានចង់ធ្វើការងារអីដែរឬទេ?

ខៈ
អឺ.....ខ្ញុំអត់មានស្រម៉ៃថាចង់ធ្វើអីនោះទេដូចថាកាលនឹងក្នុងពេលដែលខ្ញុំមានអាយុដប់ឆ្នាំនឹងខ្ញុំបានរៀនបានតិចតួចហើយណាមួយខ្ញុំកាលនឹងដូចថាវរល់តែដូចថាគេអាឡើយតែជំលៀសទៅនេះជំលៀសទៅនោះណាស់វាមិនបានដូចមានក្តីស្រម៉ៃអីនោះទេដល់ហើយអាពតនឹងវាចូលមក(សំលេងរំខានពីខាងក្រៅ)!

កៈ អូ....

ខៈ
ចាសដល់តែពេលដែលអាពតវាចូលមកនឹងហើយទៅដល់ពេលដែលចេញពីអាពតមកនឹងយើងដូចធំខ្លួនណាស់

មនុស្សយើងឆាប់ធំដូចថាខ្ញុំឆាប់ធំចឹងទៅហើយដល់ហើយម៉ែខ្ញុំគាត់ថាអោយខ្ញុំទៅរៀន ហើយទៅខ្ញុំអត់បានទៅរៀនទេខ្ញុំអឺ....ដូចថាយើងខ្លួនធំហើយចឹងណាស់រួចហើយមើលទៅម៉ែខ្ញុំទៅដូចថា....និយាយរួមយើងវាអត់ផងដូចថារៀនហើយនឹងរកលុយចិញ្ចឹមខ្លួនឯង ចិញ្ចឹមជីដូច ចិញ្ចឹមម្ដាយ!

ក៖ ចាសអ៊ី!

ខ៖ ចាសខ្ញុំ មកជីដូនខ្ញុំគាត់នៅអឺ....ជីដូនខ្ញុំគាត់នៅឯស្រុកណោះ!

ក៖ អ៊ឹម ចាស!

ខ៖ ចាស!

ក៖
ហើយទៅដូចថាកាលពីពេលដែលអ៊ីនៅជាក្មេងៗអ៊ីចូលចិត្តដូចថាមានលេងល្បែងដូចជាល្បែងកាលពីពេលដែលអ៊ីនៅជាក្មេងៗដែលគេលេងនៅក្នុងសម័យមុនៗណាស់មានល្បែងអីគេខ្លះដែលគេនិយមលេងនឹងតើអ៊ីមានធ្លាប់បានលេងដែរឬទេ?

ខ៖ មានអឺ...ល្បែងអូន មានដូចថាល្បែងចូលឆ្នាំចូលអីលេងនៅនឹងវត្តអីចឹងទៅ ឃើញគេលេងឈូងលេងទាញព្រ័តអីចឹងទៅចង់ទៅលេងនឹងគេក៏ទៅលេងនឹងគេដែរនឹងទៅ!

ក៖ អ៊ឹម បានលេងជាមួយនឹងគេដែរ(សើច)!

ខ៖ ចាសបានលេងនឹងគេដែរនឹងទៅ(សើច)
បានខែចូលឆ្នាំខ្មែរពីរបីថ្ងៃនឹងបានសុំម៉ែទៅលេងនឹងគេបានពីរបីថ្ងៃអីនឹងទៅ!

ក៖ ចាសអ៊ី!

ខ៖ ចាសអូន!

ក៖ ហើយល្បែងអីគេខ្លះដែលអ៊ីបានលេងនៅក្នុងជំនាន់នឹង?

ខ៖ ដូចថាល្បែងបោះអង្គញ់ បោះឈូងអីចឹងទៅណាស់(សំលេងរំខានពីខាងក្រៅ)!

ក៖ នៅតាមផ្ទះឬក៏លេងនៅនឹងវត្តដែរអ៊ី?

ខ៖ នៅនឹងវត្ត!

កៈ នៅវត្ត?

ខៈ ចាស!

កៈ ពេលចូលឆ្នាំ?

ខៈ ចាសៗនៅពេលចូលឆ្នាំនឹង!

កៈ ចាស ហើយចុះសំរាប់បទចំរៀងវិញកាលជំនាន់មុននឹងអ៊ីមានស្គាល់បទចំរៀងអីដែលធ្វើអោយអ៊ីចងចាំហើយអ៊ី....អ៊ីចូលចិត្តស្ដាប់ដែរឬទេ?

ខៈ (សំលេងរំខានពីខាងក្រៅ) បទចំរៀងរាំវង់រាំអីនឹងអូន!

កៈ ចាសអ៊ីចូលចិត្តបទចឹងៗន៍?

ខៈ ចាសចូលចិត្តបទរាំវង់បទញាក់កន្ត្រាក់កន្ត្រើកអីនឹងដូចជាមិនសូវជាចូលចិត្តប៉ុន្មានទេ(សើចនិងសំលេងរំខានពីខាងក្រៅ) !

កៈ (សើច) ចាស ហើយទៅបទចំរៀងកាលនៅនឹងសម័យនឹងអ៊ីអាចនៅចាំហើយអាចនៅចេះច្រៀងដែរឬទេ?

ខៈ អត់ទេអូន (សើច) អត់ចេះច្រៀងទេចេះតែស្ដាប់(សើច)!

កៈ ចាស(សើច) តែចូលចិត្តនៅតែចូលចិត្តដល់ឥលូវនឹង?

ខៈ ចាសនៅតែចូលចិត្តដល់ឥលូវនឹង(សំលេងរំខានពីខាងក្រៅ)!

កៈ ចាសហើយទៅអ្នកចំរៀងរូបណាដែរដែលធ្វើអោយចូលចិត្តហើយគាត់គឺជាអ្នកដែល(សំលេងរំខានពីខាងក្រៅ) ដូចថាអ៊ីស្ដាប់ទៅដឹងតែចូលចិត្តគាត់ម៉ងណាស់?

ខៈ ចូលចិត្តបទអី....ដូចថាយើងអី....(សំលេងរំខានពីខាងក្រៅ) បទពីដើមឬមួយក៏បទសម័យឥលូវ?

កៈ បទពីដើម....ដែលអ៊ីចូលចិត្ត?

ខ៖ បទពីដើមហ៎(សំលេងរំខានពីខាងក្រៅ)?

ក៖ ចាសអ៊ី!

ខ៖ អ៊ី...រស់ សិរីសុធាអីចឹងទៅណាស់អូន!

ក៖ ចាសហើយចុះអ៊ីមាននៅចាំចំណងជើងបទនឹងបទអីគេដែរទេអ៊ី?

ខ៖ អត់ចាំចំណងជើងនឹងថាជាបទអីគេទេ
ទាល់តែលឺបទចំរៀងមកបានដឹងថាបទនឹងហើយ(សើច)!

ក៖ (សើច)!

ខ៖ ទាល់តែលឺចឹងទៅបានចាំទៅអូន!

ក៖ ចាសអ៊ី!

ខ៖ ដូចថាចូលចិត្តដែរប៉ុន្តែដូចថាមិនចេះច្រៀងចេះអីដូចគេចឹងណាស់គេចាំអីចឹងណាស់
ចេះតែស្តាប់ហើយក៏ហើយដែរទៅណាស់(សើច) ស្តាប់ហើយភ្លេចបាត់អស់ទៅ!

ក៖
ចាសអ៊ីហើយជាចុងក្រោយអ៊ីមានពាក្យពេចជំអីដើម្បីនឹងផ្តាំផ្ញើទៅដល់ក្មេងជំនាន់ក្រោយដែល
គេបានស្តាប់សំលេងរបស់អ៊ីណាស់(សំលេងរំខានពីខាងក្រៅ)
ជាពិសេសអ្នកដែលត្រូវដូចជាសាច់ញ្ញាតិបងប្អូនរបស់អ៊ីអញ្ចឹងដែលគេបានស្តាប់សំលេងរបស់
នៅថ្ងៃនេះណាស់អ៊ី?

ខ៖ ចាសជូនពរគេអោយគេមានសុខភាពល្អ
មាំមួនអោយគេជួបប្រទះតែនឹងអ្វីដែលល្អៗកុំអោយជួបនឹងការលំបាកអីចឹងណាស់អូនទាំងអូ
នឯងអីនឹងទាំងអស់បានជោគជួយបានធ្វើការអីដែលចិត្តយើងប៉ងអោយសំរេចដូចសេចក្តីប្រា
ថ្នាណាស់!

ក៖ ចាសអ៊ី!

ខ៖ ចាសអូន!

ក៖ ចាសចឹងជាចុងក្រោយអ៊ីមានអីចង់បន្ថែមទៀតដែរឬទេ ឬក៏មានតែប៉ុន្នឹងទេ?

ខ៖ អស់ហើយអូនមានតែប៉ុន្នឹងទេអូនមានតែពាក្យជូនពរនឹង(សើច)!

កៈ ចាសអ៊ី!

ខៈ
អោយគាត់ជួបអ្វីៗដែលល្អជួបអ្វីដែលគាត់ប្រាថ្នាចឹងណាស់អោយគាត់ប្រាថ្នាអីអោយបានសំរេចដូចបំណងចឹងទៅណាស់ចាស អស់ហើយអូន!

កៈ ចាសៗអ៊ី ចាសអរគុណច្រើនអ៊ីសំរាប់ការផ្តល់ការសំភាសន៍មួយនេះចាស!